មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# កំណត់ត្រាសង្ខេប ៖ ការផ្លាស់ទីលំនៅក្នុងអំឡុងពេលមានជម្លោះព្រំដែនរវាង កម្ពុជា និងថៃ ខែធ្នូ ឆ្នាំ២០២៥

## សេចក្តីផ្តើម

នៅថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២៥ ការប្រយុទ្ធគ្នាបានចាប់ផ្តើមជាថ្មីម្តងទៀតរវាងប្រទេសកម្ពុជា និងប្រទេសថៃ បន្ទាប់មានភាពតានតឹងកើនឡើងអស់រយៈពេលជាច្រើនខែ រហូតដល់មានកិច្ចព្រមព្រៀងឈប់បាញ់ថ្ងៃទី២៨ ខែកក្កដា។ ជាលទ្ធផលនៃការប្រយុទ្ធគ្នាដែលបានអូសបន្លាយរហូតដល់បទឈប់បាញ់ត្រូវបានសម្របសម្រួលនៅថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ ២០២៥ ប្រជាជនកម្ពុជាជាងកន្លះលាននាក់ត្រូវបានផ្លាស់ទីលំនៅ។

សម្រាប់ប្រជាជនខ្មែររាប់ពាន់គ្រួសារ នេះជាលើកទីពីរហើយដែលពួកគេត្រូវបានផ្លាស់ទីលំនៅក្នុងរយៈពេលត្រឹមតែប្រាំមួយខែប៉ុណ្ណោះ ដោយមានប្រជាជនជាច្រើនត្រូវបានបង្ខំឱ្យចាកចេញពីផ្ទះសម្បែងរបស់ពួកគេក្នុងអំឡុងពេលប្រយុទ្ធគ្នាចាប់ពីថ្ងៃទី២៤ ដល់ថ្ងៃទី២៨ ខែកក្កដា។ មិនត្រឹមតែប៉ុណ្ណោះ ការប្រយុទ្ធគ្នានៅក្នុងខែធ្នូបាននាំឱ្យមានការផ្លាស់ទីលំនៅកាន់តែអូសបន្លាយ ទោះជាបទឈប់បាញ់ត្រូវបានព្រមព្រៀងគ្នាក៏ដោយ ក៏ប្រជាជនរាប់ពាន់នាក់នៅតែមិនអាចត្រឡប់ទៅផ្ទះវិញបានដែរ។ បណ្តាខេត្តដែលស្ថិតក្នុងការប្រយុទ្ធគ្នាកាលពីខែកក្កដា ឆ្នាំ២០២៥ មានខេត្តឧត្តរមានជ័យ បន្ទាយមានជ័យ ព្រះវិហារ ពោធិ៍សាត់ និងសៀមរាប បានរងផលប៉ះពាល់យ៉ាងខ្លាំង ប៉ុន្តែ ប្រតិបត្តិការយោធានៅក្នុងខែធ្នូ ឆ្នាំ២០២៥ នេះ បានរីករាលដាលរហូតដល់ខេត្តបាត់ដំបង និងកោះកុងផងដែរ។

នៅក្នុងកំណត់ត្រាសង្ខេបនេះ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា («ម.ស.ម.ក») ផ្តល់នូវទិដ្ឋភាពទូទៅនៃការផ្លាស់ទីលំនៅដែលជាលទ្ធផលនៃការប្រយុទ្ធគ្នាជាថ្មីទៀតនៅក្នុងខែធ្នូ ឆ្នាំ២០២៥ ដែលមានផលប៉ះពាល់ដល់សិទ្ធិមនុស្ស និងឧបសគ្គដែលរារាំងការវិលត្រឡប់ទៅលំនៅឋានវិញដោយសុវត្ថិភាព។ កំណត់ត្រាសង្ខេបនេះ ក៏បង្ហាញពីទស្សនៈរបស់អ្នកដែលត្រូវបានផ្លាស់ទីលំនៅជាលើកទីពីរ និងរំលេចអំពីច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងបទដ្ឋានទាក់ទងនឹងការផ្លាស់ទីលំនៅ សិទ្ធិទទួលបានដំណោះស្រាយដ៏មានប្រសិទ្ធភាពសម្រាប់អ្នករងផលប៉ះពាល់ និងចុងបញ្ចប់គឺជាអនុសាសន៍ចំពោះរាជរដ្ឋាភិបាល។

កំណត់ត្រាសង្ខេបនេះ គឺបច្ចុប្បន្នភាពនៃកំណត់ត្រាសង្ខេបដែល ម.ស.ម.ក បានចេញផ្សាយកាលពីខែកញ្ញា ឆ្នាំ២០២៥ ដោយបានគូសបញ្ជាក់ពីបទពិសោធន៍របស់អ្នកដែលបានផ្លាស់ទីលំនៅដោយសារការប្រយុទ្ធគ្នាកាលពីខែកក្កដា។



## ស្ថានភាពក្នុងអំឡុងពេលផ្លាស់ទីលំនៅ

តួលេខនៃការផ្លាស់ទីលំនៅដែលបានបង្ហាញខាងក្រោមនេះ ត្រូវបានកត់ត្រាចាប់ពីថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២៥ ដល់ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២៦ ដោយយោងតាមប្រភពជាច្រើន រួមមានក្រសួងរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ និងការរាយការណ៍របស់ប្រព័ន្ធផ្សព្វផ្សាយ៖

- ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២៥ ៖ ប្រជាជន ៤០៣.៦០១នាក់ បានផ្លាស់ទីលំនៅ
- ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៥ ៖ ប្រជាជន ៤៩៨.២៤២នាក់ បានផ្លាស់ទីលំនៅ
- ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២៥ ៖ ប្រជាជន ៥១៨.៦១១នាក់បានផ្លាស់ទីលំនៅ
- ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៥ ៖ ប្រជាជន ៦៤៤.៦៨៩នាក់ បានផ្លាស់ទីលំនៅ
- ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ៖ ប្រជាជន ៥១៧.៥៥៥នាក់ បានបន្តផ្លាស់ទីលំនៅ
- ថ្ងៃទី០១ ខែមករា ឆ្នាំ២០២៦ ៖ ប្រជាជន ៤០៩.១៤៩នាក់ បានបន្តផ្លាស់ទីលំនៅ
- ថ្ងៃទី០៨ ខែមករា ឆ្នាំ២០២៦ ៖ ប្រជាជន ១៧៣.៧៧៦នាក់ បានបន្តផ្លាស់ទីលំនៅ
- ថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៦ ៖ ប្រជាជន ១៤១.៨៥០នាក់ បានបន្តផ្លាស់ទីលំនៅ
- ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២៦ ៖ ប្រជាជន ៩៧.៨៧៨នាក់ បានបន្តផ្លាស់ទីលំនៅ
- ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៦ ៖ ប្រជាជន ៧៥.៥១១នាក់ បានបន្តផ្លាស់ទីលំនៅ
- ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៦ ៖ ប្រជាជន ៥០.៤២៥នាក់ បានបន្តផ្លាស់ទីលំនៅ
- ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២៦ ៖ ប្រជាជន ៤៧.៧១៤នាក់ បានបន្តផ្លាស់ទីលំនៅ



អ្នកផ្ដល់សម្ភាសន៍ភាគច្រើនត្រូវបានបង្ខំចិត្តឱ្យចាកចេញពីផ្ទះសម្បែងរបស់ពួកគេទៅស្នាក់នៅក្នុងជំរំភៀសសឹកដែលអាជ្ញាធរកម្ពុជាបានរៀបចំឡើង ខណៈប្រជាជនមួយចំនួនផ្សេងទៀតបានភៀសទៅស្នាក់នៅជាមួយសាច់ញាតិ ឬសហគមន៍ជិតខាង និងអ្នកផ្សេងទៀតបានទៅស្នាក់នៅក្នុងព្រៃ។

កំណត់ត្រាសង្ខេបរបស់ ម.ស.ម.ក កាលពីខែកញ្ញា ឆ្នាំ២០២៥ បានបង្ហាញពីបទពិសោធន៍របស់ប្រជាជនដែលបានផ្លាស់ទីលំនៅពីផ្ទះសម្បែងរបស់ពួកគេនៅក្នុងខេត្តពោធិ៍សាត់ ឧត្តរមានជ័យ និងព្រះវិហារ។ ក្ដីបារម្ភចម្បងបំផុតរបស់ពួកគេនៅពេលនោះគឺ ៖ ការរំលោភយកដីធ្លីដោយយោធាថៃ «ជនឱកាសនិយម» ឬ «អ្នកមានអំណាច» រួមទាំងការខូចខាតទ្រព្យសម្បត្តិខណៈដែលពួកគេត្រូវបានផ្លាស់ទីលំនៅ ការបំភាយឧស្ម័នពុលពីសំបកផ្លូវពណ៌ស ជាពិសេសការព្រួយបារម្ភរបស់ជនជាតិដើមភាគតិច និងផលប៉ះពាល់ដល់ធនធានធម្មជាតិ។ ប្រជាជនដែលបានផ្ដល់សម្ភាសន៍ដល់ ម.ស.ម.ក នាពេលនោះ បានភៀសខ្លួនដោយដោយបង្ខំដ៏គួរឲ្យសោកស្ដាយម្ដងទៀតនៅក្នុងខែធ្នូ ឆ្នាំ២០២៥។ ខាងក្រោមនេះជាទិដ្ឋភាពទូទៅនៃបញ្ហាប្រឈមដែលពួកគេ

បានជួបប្រទះ និងកង្វល់ដែលពួកគេមានក្នុងពេលភៀសខ្លួនដោយបង្ខំ ហើយនៅតែបន្តកើតមាន ទោះបីជាពួកគេទាំងអស់អាចបានត្រឡប់មកផ្ទះរបស់ពួកគេវិញហើយក៏ដោយៈ

- អ្នកខ្លះត្រូវបានអាជ្ញាធរណែនាំឱ្យចាកចេញពីផ្ទះរបស់ពួកគេ ខណៈដែលអ្នកខ្លះទៀតចាកចេញដោយខ្លួនឯងដោយការបារម្ភពីសុវត្ថិភាព។
- រយៈពេលដែលពួកគេបានផ្លាស់ទីលំនៅគឺមានរយៈពេលចាប់ពីមួយខែទៅពីរខែ។
- ប្រជាជនខ្លះដែលបានផ្តល់សម្ភាសន៍ដល់ ម.ស.ម.ក មិនបានស្នាក់នៅក្នុងជំរំភៀសសឹកដែលគ្រប់គ្រងដោយអាជ្ញាធរទេ ប៉ុន្តែពួកគេបានស្នាក់នៅក្នុងព្រៃ ជាមួយសាច់ញាតិ ឬនៅក្នុងភូមិផ្សេងទៀត ព្រោះពួកគេខ្វះធនធានក្នុងការដឹកជញ្ជូនដើម្បីធ្វើដំណើរពីភូមិរបស់ពួកគេទៅកាន់ជំរំទាំងនោះដែលមានចម្ងាយប្រមាណពី ៧០ ទៅ ៨០ គីឡូម៉ែត្រ ពួកគេក៏មិនចង់ឃ្លាតឆ្ងាយពីផ្ទះសម្បែងរបស់ពួកគេទេ ហើយមានការព្រួយបារម្ភអំពីលទ្ធភាពនៃការវាយប្រហារតាមអាកាសរបស់យោធាថៃ ដែលនឹងកំណត់គោលដៅទៅលើក្រុមមនុស្សដែលមានចំនួនច្រើនដូចជានៅក្នុងជំរំជាដើម។
- ប្រជាជនទាំងអស់នោះបានជួបការលំបាកក្នុងការទទួលបានជំនួយគ្រប់គ្រាន់។ អ្នកខ្លះដែលបានទទួលអំណោយពីអាជ្ញាធរបានបញ្ជាក់ថាបានទទួលក្នុងបរិមាណតិចតួចប៉ុណ្ណោះ។ ប្រជាជនម្នាក់នៅក្នុងខេត្តព្រះវិហារបាននិយាយថា គ្រួសារគាត់ទទួលបានត្រឹមតែមីប្រាំកញ្ចប់ អង្ករ ៥គីឡូក្រាម ទឹកស៊ីអ៊ីវប្អូនដប និងទឹកត្រីពីរដបប៉ុណ្ណោះ។ អ្នកខ្លះក៏បានទទួលអំណោយពីអង្គការសង្គមស៊ីវិលផងដែរ។ ប្រជាជនដែលបានស្នាក់នៅក្នុងព្រៃបានបញ្ជាក់ថា ពួកគេមិនបានទទួលអំណោយពីអាជ្ញាធរទេ និងបានអំពាវនាវដល់អាជ្ញាធរជានាថា ជំនួយត្រូវបានចែកចាយដល់អ្នកដែលត្រូវបានផ្លាស់ទីលំនៅទាំងអស់ ហើយពួកគេត្រូវទទួលបានការគាំទ្រដែរ គឺមិនមែនត្រឹមតែអ្នកដែលស្នាក់នៅក្នុងជំរំភៀសឹកផ្លូវការនោះទេ។
- ជាសំណាងល្អ ពុំមានផ្ទះរបស់ប្រជាជនណាម្នាក់ដែលបានផ្តល់សម្ភាសន៍ដល់ ម.ស.ម.ក ត្រូវបានខូចខាតដោយសារការប្រយុទ្ធគ្នានោះទេ។ ប្រជាជនម្នាក់បានចែករំលែកថា ផ្ទះចំនួនប្រាំខ្នងនៅក្នុងតំបន់ជិតខាងគាត់ត្រូវបានខូចខាតដោយការបាញ់ផ្លោង ប៉ុន្តែពុំមានបុគ្គលណាម្នាក់ជាម្ចាស់ផ្ទះដែលរងផលប៉ះពាល់នោះបានទទួលសំណងណាមួយឡើយ។
- ជីវភាពរស់នៅរបស់ពួកគាត់ក៏រងផលប៉ះពាល់ផងដែរ ដោយប្រជាជនម្នាក់បាននិយាយថា ដំណាំរបស់គាត់បានងាប់ដោយសារតែការផ្លាស់ទីលំនៅ ព្រោះមិនអាចថែទាំស្រោចទឹកដំណាំទាំងនោះបាន។ នេះជាផលប៉ះពាល់យ៉ាងខ្លាំងទៅលើប្រាក់ចំណូលរបស់គ្រួសារគាត់ ហើយពួកគេក៏មិនទាន់ទទួលបានសំណងណាមួយដែរ។

- ក្តីបារម្ភមួយរបស់ប្រជាជនទាំងអស់ដែលផ្តល់សម្ភាសន៍ដល់ ម.ស.ម.ក គឺការរំលោភយកដីធ្លី។ ពួកគេលើកឡើងថា ដីរបស់ពួកគេអាចនឹងត្រូវរំលោភយកដោយយោធាថៃ ឬដោយជនឱកាសនិយមដែលមានបំណងឈ្លានពានយកដីរបស់ពួកគេ និង/ឬលួចទ្រព្យសម្បត្តិរបស់ពួកគេ។ ពួកគេក្រែងថារឿងនេះនឹងធ្វើឱ្យពួកគេក្លាយជាជនគ្មានដីធ្លី គ្មានផ្ទះសម្បែង និងគ្មានលទ្ធភាពអាស្រ័យផលលើធនធានធម្មជាតិ ជាពិសេសសនោះគឺជនជាតិដើមភាគតិច។ ការបាត់បង់ដីស្រែ និងដំណាំក៏ជាក្តីបារម្ភដ៏សំខាន់មួយដែលប្រជាជនជាច្រើនបានលើកឡើង ពីព្រោះជាប្រភពចំណូលនិងជាមធ្យោបាយចិញ្ចឹមជីវិតរបស់ពួកគេ។ គួរកត់សម្គាល់ថាក្តីបារម្ភទាំងអស់នេះ មិនត្រឹមតែជាការទទួល អារម្មណ៍នៅពេលដែលប្រជាជនទាំងនោះត្រូវបានផ្លាស់ទីលំនៅប៉ុណ្ណោះទេ ប៉ុន្តែនៅតែជាការប្រុងប្រយ័ត្នខ្ពស់ជានិច្ច បើទោះជាមានបទឈប់បាញ់ក៏ដោយ។ នេះបង្ហាញពីកាលៈទេសៈដ៏លំបាកខ្លាំងដែលកំពុងដក់នៅក្នុងចិត្តរបស់មនុស្សជាច្រើន។
- អ្នកទាំងអស់ដែលបានផ្តល់សម្ភាសន៍ដល់ ម.ស.ម.ក បានបង្ហាញពីអារម្មណ៍អសុវត្ថិភាព និងភាពមិនប្រាកដប្រជាជារៀងរហូត មិនត្រឹមតែបច្ចុប្បន្នកាលប៉ុណ្ណោះទេ ប៉ុន្តែក៏គិតអំពីអនាគតផងដែរ។ បុគ្គលម្នាក់បានចែករំលែកថា គាត់មិនមានអារម្មណ៍សុវត្ថិភាពនោះឡើយ គឺចាប់តាំងពីជម្លោះព្រំដែនបានចាប់ផ្តើមដំបូងមកម្លេះ ហើយថាគាត់ និងគ្រួសារនៅតែត្រៀមខ្លួនជម្លៀសចេញពីផ្ទះរបស់ពួកគេជាលើកទីបី ប្រសិនបើការប្រយុទ្ធគ្នានឹងកើតមានម្តងទៀត។

## ឧបសគ្គក្នុងការវិលត្រឡប់មកផ្ទះសម្បែងវិញ

ខណៈពេលដែលប្រជាជនទាំងនោះអាចវិលត្រឡប់ទៅផ្ទះសម្បែងរបស់ពួកគេវិញបាន បើទោះជាកំពុងឋិតក្នុងអស្ថិរភាពក៏ដោយ ក៏ប្រជាជនកម្ពុជារាប់ពាន់នាក់នៅតែមិនអាចវិលត្រឡប់ទៅផ្ទះសម្បែងរបស់ពួកគេវិញបាន។ នៅចុងខែកុម្ភៈ ទិន្នន័យពីក្រសួងព័ត៌មានបានបង្ហាញថា ប្រជាជនកម្ពុជាជាង ៥០.០០០នាក់ នៅតែកំពុងបន្តផ្លាស់ទីលំនៅ ខណៈអង្គការមួយចំនួនបានប៉ាន់ប្រមាណថា ចំនួននេះអាចធ្លាក់មកនៅត្រឹម ៤៧.០០០ នាក់ គិតត្រឹមដើមខែមីនា ឆ្នាំ២០២៦នេះ។

មានកត្តាជាច្រើនបានរួមចំណែកដល់ការផ្លាស់ទីលំនៅដែលអូសបន្លាយនេះ គឺមានរយៈពេលរហូតដល់ទៅ៦០ថ្ងៃបន្ទាប់ពីបទឈប់បាញ់ត្រូវបានចុះហត្ថលេខា។ ការបិទផ្លូវដោយដាក់ពង្រាយកុងតឺន័រ និងលួសបន្លាដែលធ្វើឡើងដោយយោធាថៃនៅក្នុងតំបន់ដែលយោធាថៃអះអាងថាជាទឹកដីថៃ បានរារាំងប្រជាជនកម្ពុជាជាច្រើនក្នុងការវិលត្រឡប់ទៅផ្ទះរបស់ពួកគេវិញ។ ចំពោះអ្នកផ្សេងទៀត ការបាត់បង់អស់ផ្ទះសម្បែងរបស់ពួកគេគឺជាឧបសគ្គដែលមិនអាចវិលត្រឡប់ទៅផ្ទះវិញបាន។ យោងតាមទិន្នន័យពីក្រសួងមហាផ្ទៃ នៅចុងខែកុម្ភៈ មានផ្ទះប្រមាណ ៩៨០ខ្នង ត្រូវបានខូចខាត។

ក្នុងអំឡុងពេលសរសេរកំណត់ត្រាសង្ខេបនេះ ម.ស.ម.ក បានសង្កេតឃើញថា មិនទាន់មានព័ត៌មានណាមួយដែលបានចេញផ្សាយទាក់ទងនឹងនីតិវិធីទាមទារការស្តារឡើងវិញ ឬសំណងសម្រាប់បុគ្គលដែលផ្ទះរបស់ពួកគេត្រូវបានខូចខាត ឬបំផ្លាញក្នុងអំឡុងពេលមានជម្លោះ ឬទ្រព្យសម្បត្តិរបស់ពួកគេត្រូវបានខូចខាត ឬ

ត្រូវបានលួចនោះទេ។ ប្រសិនបើយន្តការបែបនេះត្រូវបានបង្កើតឡើង ព័ត៌មានអំពីនីតិវិធី និងរបៀបចូលមើលនីតិវិធីនោះគួរតែត្រូវបានផ្សព្វផ្សាយដល់សាធារណជនយ៉ាងទូលំទូលាយ និងពីរបៀបដែលអាចចូលមើលបាន។

ការផ្ដួចផ្ដើមគំនិតរបស់រាជរដ្ឋាភិបាលក្នុងការសាងសង់ផ្ទះបណ្ដោះអាសន្នប្រមាណចំនួន ៣.០០០ ខ្នងសម្រាប់ប្រជាជនដែលកំពុងបន្តការផ្លាស់ប្តូរទីលំនៅក្នុងខេត្តបន្ទាយមានជ័យ ព្រះវិហារ និងឧត្តរមានជ័យ គឺជាគំនិតផ្ដួចផ្ដើមដ៏គួរសាទរ ក្នុងគោលបំណងផ្ដល់ឱ្យប្រជាជនទាំងនេះនូវមធ្យោបាយស្នាក់នៅបណ្ដោះអាសន្នដែលប្រើប្រាស់បានយូរ មានសុវត្ថិភាព និងសុខស្រួលជាងមុន ជាពិសេសមុនរដូវវស្សាមកដល់។ ថ្មីៗនេះ មានប្រជាជនចំនួន ២០៣គ្រួសារ នៃជនភៀសសឹក នៅក្នុងក្រុងសំរោង និងស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ បានទទួលផ្ទះពីរាជរដ្ឋាភិបាលកម្ពុជា និងបានប្រគល់ដោយផ្ទាល់ដល់ប្រជាជនទាំងនោះដោយរដ្ឋបាលខេត្ត។ មានការខ្វះខាតហេដ្ឋារចនាសម្ព័ន្ធសង្គម និងសេវាគាំទ្រត្រូវបានលើកឡើងដោយអ្នកឃ្លាំមើលមួយចំនួន។ ម.ស.ម.ក យល់ថា ផ្ទះទាំងនោះត្រូវតែនៅតែជាផ្ទះបណ្ដោះអាសន្ន។ ផ្ទះទាំងនោះមិនត្រូវក្លាយជាផ្ទះជំនួស ឬជំនួសផ្ទះដែលខូចខាត ឬត្រូវបានបំផ្លាញនោះទេ ប៉ុន្តែជាដំណោះស្រាយរយៈពេលខ្លីប៉ុណ្ណោះ ខណៈពេលដែលយន្តការស្តាររជីវភាពឡើងវិញកំពុងត្រូវបានអនុវត្ត ឬមិនដូច្នោះទេ វិធានការសំណងអាចត្រូវបានអនុវត្ត។



អ្នកដែលត្រូវបានផ្លាស់ទីលំនៅមិនត្រឹមតែមិនអាចវិលត្រឡប់មកផ្ទះវិញបាន ដោយសារតែការខូចខាត ឬការបំផ្លិចបំផ្លាញផ្ទះសម្បែងរបស់ពួកគេប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានការរំខានយ៉ាងខ្លាំងដល់សេវាកម្មផងដែរ ដូចជា សាលារៀន និងមន្ទីរពេទ្យត្រូវបានបិទអស់រយៈពេលយូរ រួមមានទាំងការិយាល័យឃុំ ស្ថានីយ៍ប៉ូលីស អាងស្តុកទឹក និងប្រព័ន្ធទឹកស្អាត កន្លែងផ្គត់ផ្គង់អគ្គិសនី និងបង្គោលអង់តែនទូរស័ព្ទចំនួនពីរ។ ផ្លូវថ្នល់ និងស្ពានក៏ត្រូវបានខូចខាតផងដែរដែលរារាំងដល់ភាពងាយស្រួលនៃការធ្វើដំណើរ និងល្បឿនដែលជីវិតធម្មតាអាចបន្តឡើងវិញ។ របាយការណ៍បានបង្ហាញថា នៅក្នុងតំបន់ខ្លះគ្រួសារដែលបានចាកចេញពីជំរំភៀសសឹកដើម្បីត្រឡប់ទៅផ្ទះវិញ ប៉ុន្តែក្រោយមកក៏បានត្រឡប់ទៅជំរំនេះវិញដោយសារតែពុំមានសេវាកម្មគ្រប់គ្រាន់តាមតម្រូវការ ការខូចខាតទ្រព្យសម្បត្តិ និងការរឹតបន្តឹងសុវត្ថិភាព។

ក្តីបារម្ភដ៏សំខាន់មួយទៀតដែលរារាំងការវិលត្រឡប់ទៅផ្ទះសម្បែងវិញរបស់ប្រជាជននោះ គឺគ្រាប់មិនទាន់ផ្ទុះដែលបង្កគ្រោះថ្នាក់ដល់សុវត្ថិភាពយ៉ាងធ្ងន់ធ្ងរ។ លើសពីនោះទៀត ទោះជានឹងមានកិច្ចខិតខំប្រឹងប្រែងដើម្បីសម្អាតគ្រាប់មិនទាន់ផ្ទុះទាំងនេះដែលនឹងត្រូវបញ្ចប់ទាំងស្រុង ដោយប្រើរយៈពេលយូរនោះ វត្តមាននៃគ្រាប់មិនទាន់ផ្ទុះទាំងនេះនឹងបង្កហានិភ័យខ្ពស់ណាស់ដល់កសិករផងដែរ។ ទាំងនេះហើយជាផលប៉ះពាល់ដល់សមត្ថភាពរបស់ប្រជាជនក្នុងការរកប្រាក់ចិញ្ចឹមជីវិត ដែលត្រូវបានបំផ្លាញដោយការប្រយុទ្ធគ្នាទាំងពីរលើកចាប់តាំងពីខែកក្កដា ឆ្នាំ២០២៥ មក។

## ច្បាប់ និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ

ច្បាប់ជាមូលដ្ឋានមួយនៃច្បាប់អន្តរជាតិបានពន្យល់ថា ការស្តារឡើងវិញត្រូវធ្វើឡើងចំពោះការរំលោភលើច្បាប់អន្តរជាតិ។ ជាពិសេស មាត្រា ៣១ របស់អង្គការសហប្រជាជាតិស្តីពីការទទួលខុសត្រូវរបស់រដ្ឋចំពោះទង្វើខុសច្បាប់អន្តរជាតិ បានចែងអំពីរដ្ឋដែលត្រូវទទួលខុសត្រូវចំពោះទង្វើខុសច្បាប់អន្តរជាតិត្រូវតែជុសជុលពេញលេញសម្រាប់ការខូចខាតដែលខ្លួនបានបង្កឡើង។[1] មាត្រា ៣៦ ៖ រដ្ឋដែលទទួលខុសត្រូវត្រូវតែផ្តល់សំណងសម្រាប់ការខូចខាតដែលអាចវាយតម្លៃបានផ្នែកហិរញ្ញវត្ថុ ប្រសិនបើការស្តារជីវភាពឡើងវិញមិនអាចប្រព្រឹត្តទៅបានទេ។ លើសពីនេះ នៅក្នុងច្បាប់មនុស្សធម៌អន្តរជាតិ (អនុសញ្ញាទីក្រុងហ្សឺណែវ និងពិធីសារបន្ថែមទី I) ក៏បានចែងពីកាតព្វកិច្ចក្នុងការផ្តល់សំណងដល់ជនរងគ្រោះនៃការរំលោភបំពានច្បាប់មនុស្សធម៌អន្តរជាតិ។ ជាពិសេស វិធាន ១៥០ នៃច្បាប់ទំនៀមទម្លាប់មនុស្សធម៌អន្តរជាតិរបស់គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ (អាយ.ស៊ី.អ.ស៊ី) បានចែងថា «រដ្ឋដែលទទួលខុសត្រូវចំពោះការរំលោភបំពានច្បាប់មនុស្សធម៌អន្តរជាតិ ត្រូវបានតម្រូវឱ្យផ្តល់ការស្តារឡើងវិញពេញលេញសម្រាប់ការបាត់បង់ ឬរបួសដែលខ្លួនបានបង្កឡើង»។[2]

ដូចដែលបានពន្យល់នៅក្នុងកំណត់ត្រាសង្ខេបមុនរបស់ ម.ស.ម.ក ស្តីពីការផ្លាស់ទីលំនៅ ច្បាប់សិទ្ធិមនុស្សអន្តរជាតិធានាសិទ្ធិទទួលបានដំណោះស្រាយប្រកបដោយប្រសិទ្ធភាព ចំពោះប្រជាជនដែលទទួលរងការរំលោភសិទ្ធិមនុស្ស។ ជាពិសេស សិទ្ធិនេះត្រូវបានធានាដោយមាត្រា ២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ក.អ.ស.ព.ន) ដែលកម្ពុជាបានផ្តល់សច្ចាប័នក្នុងឆ្នាំ ១៩៩២។ ធាតុផ្សំមួយនៃមធ្យោបាយដោះស្រាយដ៏មានប្រសិទ្ធភាពគឺជុសជុលការខូចខាតដែលអាចប្រើទម្រង់ជា «ការស្តារជីវភាពឡើងវិញ» គឺការប្រគល់ដល់ជនរងគ្រោះនូវទីតាំងដែលពួកគេធ្លាប់មានមុនពេលមានការរំលោភបំពាន ឬប្រសិនបើមិនអាចធ្វើទៅបានតាមមធ្យោបាយនេះទេ គឺត្រូវផ្តល់ជាសំណង។ ជាផ្នែកសំខាន់បំផុតនៃច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដែលគូសបញ្ជាក់ពីកាតព្វកិច្ចរបស់រដ្ឋចំពោះការស្តារឡើងវិញ គឺជាគោលការណ៍ណែនាំជាមូលដ្ឋានរបស់អង្គការសហប្រជាជាតិ ស្តីពីសិទ្ធិទទួលបានការដោះស្រាយ និងការស្តារឡើងវិញ សម្រាប់ជនរងគ្រោះនៃការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ («គោលការណ៍របស់អង្គការសហប្រជាជាតិ ស្តីពីដំណោះស្រាយ និងការស្តារឡើងវិញ»)។ គោលការណ៍ទាំងនេះត្រូវបានអនុម័តដោយមហាសន្និបាតរបស់អង្គការសហប្រជាជាតិនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៥។ គោលការណ៍ទី២ «វិសាលភាពនៃកាតព្វកិច្ច» ចែងថា៖

៣. កាតព្វកិច្ចគោរព ធានា និងអនុវត្តច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងច្បាប់មនុស្សធម៌អន្តរជាតិ ដូចដែលមានចែងក្នុងច្បាប់ដែលរដ្ឋនីមួយត្រូវអនុវត្ត រួមមាន កាតព្វកិច្ចក្នុងការ៖

(គ) ផ្តល់ជូនអ្នកដែលអះអាងថាជាជនរងគ្រោះនៃការរំលោភសិទ្ធិមនុស្ស ឬច្បាប់មនុស្សធម៌ នូវសិទ្ធិទទួលបានយុត្តិធម៌ស្មើភាពគ្នា និងមានប្រសិទ្ធភាព ដូចដែលបានពិពណ៌នាខាងក្រោម ដោយមិនគិតពីតួអង្គណាជាអ្នកទទួលខុសត្រូវចំពោះការរំលោភបំពាននោះឡើយ។

[1] មហាសន្និបាតអង្គការសហប្រជាជាតិ, 'អត្ថបទស្តីពីការទទួលខុសត្រូវរបស់រដ្ឋចំពោះទង្វើខុសច្បាប់អន្តរជាតិ', (២០០០), អេ/អអ៊ីអែស/៥៦/៨៣, https://legal.un.org/ilc/texts/instruments/english/draft_articles/9_6_2001

[2] គណៈកម្មាធិការអន្តរជាតិនៃកាកបាទក្រហម (អាយ.ស៊ី.អ.ស៊ី) ច្បាប់ទំនៀមទម្លាប់អន្តរជាតិ៖ វិធាន ១៥០ – ការស្តារឡើងវិញ, https://ihl-databases.icrc.org/en/customary-ihl/v1/rule150

(ឃ) ផ្តល់ដំណោះស្រាយប្រកបដោយប្រសិទ្ធភាពដល់ជនរងគ្រោះ រួមទាំងការស្តារឡើងវិញផងដែរ។[3]

លើសពីនេះ គោលការណ៍ទី៩ ចែងថា៖

១៥. ក្នុងករណីដែលបុគ្គល នីតិបុគ្គល ឬអង្គភាពផ្សេងទៀតត្រូវបានរកឃើញថាមានកាតព្វកិច្ចផ្តល់ការស្តារឡើងវិញដល់ជនរងគ្រោះ ភាគីនោះត្រូវផ្តល់ការស្តារឡើងវិញដល់ជនរងគ្រោះ ឬផ្តល់សំណងដល់រដ្ឋ ប្រសិនបើរដ្ឋនោះបានផ្តល់ការស្តារឡើងវិញដល់ជនរងគ្រោះរួចហើយ។[4]

គោលការណ៍ទី៩ បានចែងទៀតថា ៖

១៦. រដ្ឋនានាគួរខិតខំបង្កើតកម្មវិធីជាតិសម្រាប់ការស្តារឡើងវិញ និងជំនួយផ្សេងៗទៀតដល់ជនរងគ្រោះ ក្នុងករណីដែលភាគីទទួលខុសត្រូវចំពោះគ្រោះថ្នាក់ដែលរងទុក្ខមិនអាច ឬមិនមានឆន្ទៈក្នុងការបំពេញកាតព្វកិច្ចរបស់ពួកគេ។[5]

ដូចនេះ តាមច្បាប់សិទ្ធិមនុស្សអន្តរជាតិចែងថា រដ្ឋមួយមានកាតព្វកិច្ចផ្តល់ការស្តារឡើងវិញដល់ជនរងគ្រោះនៃការរំលោភសិទ្ធិមនុស្ស ឬច្បាប់មនុស្សធម៌ ប្រសិនបើអ្នកប្រព្រឹត្តខុសមិនមានឆន្ទៈឬមិនអាចធ្វើបាន។ ក្នុងករណីនេះ រដ្ឋដែលត្រូវបានរកឃើញថាទទួលខុសត្រូវចំពោះការរំលោភបំពានត្រូវផ្តល់សំណងដល់រដ្ឋដែលបានផ្តល់សំណងដល់ជនរងគ្រោះនៅពេលក្រោយ។ ដូច្នេះ លទ្ធភាពតាមផ្លូវច្បាប់អន្តរជាតិ រាជរដ្ឋាភិបាលកម្ពុជាអាចទាមទារសំណងពីប្រទេសថៃសម្រាប់ការខូចខាតដល់ផ្ទះសម្បែង ទ្រព្យសម្បត្តិ និងហេដ្ឋារចនាសម្ព័ន្ធរបស់ជនស៊ីវិលក្នុងអំឡុងពេលជម្លោះ។ ទោះជាយ៉ាងណាក៏ ដោយសារកាលៈទេសៈបច្ចុប្បន្ន ដែលការចរចារវាងរដ្ឋទាំងពីរកំពុងដំណើរការ និងអាចចំណាយពេលយូរ រាជរដ្ឋាភិបាលកម្ពុជាអាចពិចារណាបន្តការអនុវត្តយន្តការស្តារឡើងវិញសម្រាប់ជនរងគ្រោះ និងអាចទាមទារសំណងសម្រាប់ការខូចខាតបែបនេះពីប្រទេសថៃនាពេលដែលសមគួរណាមួយ។ ដូចនេះ គឺមានសារៈសំខាន់ណាស់ដែលជនស៊ីវិលរងផលប៉ះពាល់ដោយជម្លោះមិនត្រូវបានបដិសេធសិទ្ធិរបស់ពួកគេក្នុងការទទួលបានដំណោះស្រាយប្រកបដោយប្រសិទ្ធភាព និងសិទ្ធិរបស់ពួកគេក្នុងការទទួលបានលំនៅឋានសមរម្យ ខណៈដែលការចចារវាងភាគីទាំងសងខាងកំពុងដំណើរការដោយមានរយៈពេលយូរ។

គោលការណ៍ទី ៩ គូសបញ្ជាក់បន្ថែមទៀតអំពីលក្ខខណ្ឌសម្រាប់សំណង ដូចខាងក្រោម ៖

២០. សំណងគួរត្រូវបានផ្តល់ជូនសម្រាប់ការខូចខាតដែលអាចវាយតម្លៃបានខាងសេដ្ឋកិច្ចណាមួយតាមការសមស្រប និងសមាមាត្រទៅនឹងភាពធ្ងន់ធ្ងរនៃការរំលោភបំពាន និងកាលៈទេសៈនៃករណីនីមួយៗ ដែលបណ្តាលមកពីការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ ដូចជា៖

(ក) គ្រោះថ្នាក់ផ្លូវកាយ ឬផ្លូវចិត្ត

(ខ) ឱកាសដែលបាត់បង់ រួមទាំងការងារ ការអប់រំ និងអត្ថប្រយោជន៍សង្គម

---

[3] មហាសន្និបាតអង្គការសហប្រជាជាតិ, 'គោលការណ៍ និងគោលការណ៍ណែនាំជាមូលដ្ឋានស្តីពីសិទ្ធិទទួលបានដំណោះស្រាយ និងការស្តារឡើងវិញសម្រាប់ជនរងគ្រោះនៃការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ', អេ/អ អ៊ីអែស/៦០/១៤៧, (២០០៦), គោលការណ៍ ២(៣), ទំព័រ ៤

[4] ប្រពភដូចខាងលើ, គោលការណ៍ទី៩ (១៥)

[5] ប្រពភដូចខាងលើ, គោលការណ៍ទី៩ (១៦)

(គ) ការខូចខាតសម្ភារៈ និងការបាត់បង់ប្រាក់ចំណូល រួមទាំងការបាត់បង់សក្តានុពលនៃការរកប្រាក់ចំណូល

(ឃ) ការខូចខាតខាងសីលធម៌;

(ង) ការចំណាយដែលត្រូវការសម្រាប់ជំនួយផ្នែកច្បាប់ ឬជំនាញ សេវាវេជ្ជសាស្ត្រ និងសេវាផ្លូវចិត្ត និងសង្គម។[6]

ក្នុងករណីដែលយន្តការផ្តល់សំណងបែបនេះត្រូវបានបង្កើតឡើង ព័ត៌មានអំពីការចូលប្រើយន្តការនោះត្រូវតែផ្សព្វផ្សាយដោយអាជ្ញាធរពាក់ព័ន្ធ ដូចដែលបានចែងក្នុងគោលការណ៍ទី ១០ ៖

២៤. រដ្ឋគួរបង្កើតមធ្យោបាយដើម្បីជូនដំណឹងដល់សាធារណជនទូទៅ និងជាពិសេសជនរងគ្រោះនៃការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ អំពីសិទ្ធិ និងដំណោះស្រាយដែលត្រូវបានដោះស្រាយដោយគោលការណ៍ និងគោលការណ៍ណែនាំជាមូលដ្ឋានទាំងនេះ និងអំពីសេវាកម្មផ្នែកច្បាប់ វេជ្ជសាស្ត្រ ផ្លូវចិត្ត សង្គម រដ្ឋបាល និងសេវាកម្មផ្សេងទៀតទាំងអស់ដែលមាន ដើម្បីធានាថាជនរងគ្រោះមានសិទ្ធិទទួលបាន។[7]

ទាក់ទងនឹងការស្តារឡើងវិញសម្រាប់លំនៅឋាន និងទ្រព្យសម្បត្តិជាពិសេស គោលការណ៍ទី២ នៃគោលការណ៍អង្គការសហប្រជាជាតិឆ្នាំ ២០០៥ ស្តីពីការស្តារឡើងវិញចំពោះលំនៅឋាន និងទ្រព្យសម្បត្តិសម្រាប់ជនភៀសខ្លួន និងជនផ្លាស់ទីលំនៅ («គោលការណ៍ ភីនហេរ៉ូ») ចែងថា៖ «ជនភៀសខ្លួន និងជនផ្លាស់ទីលំនៅទាំងអស់មានសិទ្ធិស្តារលំនៅឋាន ដីធ្លី និង/ឬទ្រព្យសម្បត្តិណាមួយដែលពួកគេត្រូវបានដកហូតដោយបំពាន ឬខុសច្បាប់ ឬទទួលបានសំណងសម្រាប់លំនៅឋាន ដីធ្លី និង/ឬទ្រព្យសម្បត្តិណាមួយដែលមិនអាចស្តារឡើងវិញបានដូចដើម ដែលបានកំណត់ដោយតុលាការឯករាជ្យ និងមិនលំអៀង»។ អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិមានលំនៅឋាន បានគូសបញ្ជាក់អំពីរបៀបដែលសំណងបែបនេះគួរតែត្រូវបានផ្តល់ប្រកបដោយប្រសិទ្ធភាព៖

- ដីធ្លី៖ «សំណងជាប្រាក់មិនគួរជំនួសសំណងពិតប្រាកដក្នុងទម្រង់ជាដីធ្លី និងធនធានទ្រព្យសម្បត្តិរួមនោះទេ។ ដូច្នេះ ក្នុងករណីដែលដីធ្លីត្រូវបានដកហូត ជនរងគ្រោះគួរតែត្រូវបានផ្តល់សំណងជាដីដែលសមស្រប ឬប្រសើរជាងនេះទាក់ទងនឹងគុណភាព ទំហំ និងតម្លៃ»។[8]
- ជីវភាពរស់នៅ៖ «សំណងគួរតែត្រូវបានផ្តល់ជូនសម្រាប់ការខូចខាតដែលអាចវាយតម្លៃបានខាងសេដ្ឋកិច្ច។ ក្នុងករណីដែលផ្ទះ និងដីធ្លីក៏ជាប្រភពនៃការចិញ្ចឹមជីវិតផងដែរ ដូចនេះសំណងក៏ត្រូវតែគិតគូរពីតម្លៃនៃការខាតបង់អាជីវកម្ម ឧបករណ៍/សារពើភ័ណ្ឌ សត្វពាហនៈ ដីធ្លី ដើមឈើ/ដំណាំ និងប្រាក់ឈ្នួល/ប្រាក់ចំណូលដែលបាត់បង់/ថយចុះ»។[9]

---

[6] គោលការណ៍របស់អង្គការសហប្រជាជាតិស្តីពីដំណោះស្រាយ និងការស្តារឡើងវិញ, គោលការណ៍ទី ៩ (២០)

[7] ប្រភពដូចខាងលើ, គោលការណ៍ទី១០ (២៤)

[8] មហាសន្និបាតអង្គការសហប្រជាជាតិ របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីលំនៅឋានសមរម្យជាសមាសធាតុមួយនៃសិទ្ធិទទួលបានបទដ្ឋានរស់នៅសមរម្យ និងសិទ្ធិមិនរើសអើងក្នុងបរិបទនេះ បាឡាគ្រីសណាន រ៉ាចាហ្គោប៉ាល់ - សិទ្ធិទទួលបានលំនៅឋានសមរម្យក្នុងអំឡុងពេលជម្លោះហិង្សា អេ/៧៧/១៩០, (២០២២), ទ៧៤

[9] ប្រភពដូចខាងលើ

## អនុសាសន៍

**១. ម.ស.ម.ក. សូមអំពាវនាវដល់រដ្ឋាភិបាលកម្ពុជាអនុវត្តអនុសាសន៍ដូចខាងក្រោម ៖**

i. ធានា និងសម្រួលដល់ការវិលត្រឡប់ដោយសុវត្ថិភាព និងដោយស្ម័គ្រចិត្តរបស់បុគ្គលដែលត្រូវបានផ្លាស់ទីលំនៅក្នុងអំឡុងពេលជម្លោះទៅកាន់ផ្ទះសម្បែង និងដីធ្លីរបស់ពួកគេ។

ii. ចំពោះអ្នកដែលមិនទាន់អាចវិលត្រឡប់ទៅផ្ទះ និងដីធ្លីរបស់ពួកគេវិញដោយសុវត្ថិភាព សូមធានាឱ្យពួកគេទទួលបានជម្រក អាហារ ទឹក សេវាថែទាំសុខភាព និងអនាម័យគ្រប់គ្រាន់ខណៈពេលដែលពួកគេនៅតែត្រូវបានផ្លាស់ទីលំនៅ។

iii. បង្កើតនីតិវិធីទាមទារការស្តារឡើងវិញ និងសំណងឱ្យបានឆាប់សម្រាប់អ្នកដែលទ្រព្យសម្បត្តិរបស់ពួកគេត្រូវបានខូចខាត ឬបំផ្លាញដោយសារជម្លោះ។ ធានាថានីតិវិធីនៃការស្តារឡើងវិញ និងសំណងបែបនេះត្រូវបានបង្កើតឡើងដែលអាចដំណើរការបាន និងត្រូវបានអនុវត្តដោយគ្មានការរើសអើង ដោយយកចិត្តទុកដាក់ជាពិសេសដើម្បីធានាថាស្ត្រី សហគមន៍ជនជាតិដើមភាគតិច ជនពិការ និងក្រុមដែលងាយរងគ្រោះផ្សេងទៀតអាចទទួលបាននីតិវិធីទាំងនេះយ៉ាងពេញលេញ។ នីតិវិធីទាមទារសំណងបែបនេះអាចទទួលស្គាល់ថាជាការទទួលខុសត្រូវរបស់ប្រទេសថៃ ប៉ុន្តែមិនគួរពន្យារពេលអនុវត្តនីតិវិធីនេះដោយការរំពឹងរង់ចាំទាល់តែមានការទូទាត់សំណងពីប្រទេសថៃជាមុននោះទេ។

iv. ធានាថាព័ត៌មានច្បាស់លាស់ និងអាចចូលមើលបានអំពីនីតិវិធីទាំងនេះត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយ តាមរយៈទម្រង់ច្រើនយ៉ាង។

v. ទប់ស្កាត់ការរំលោភយកដីធ្លីដោយខុសច្បាប់ និងក្នុងករណីដែលកើតឡើង ត្រូវធានាថាជនរងគ្រោះទទួលបានយុត្តិធម៌យ៉ាងឆាប់រហ័ស។

**២. ម.ស.ម.ក អំពាវនាវដល់ភាគីទាំងពីរនៃជម្លោះព្រំដែន គឺរាជរដ្ឋាភិបាលកម្ពុជា និងរាជរដ្ឋាភិបាលថៃ សូមគោរពអធិបតេយ្យភាពរបស់ប្រទេសនីមួយៗ ដោយប្តេជ្ញាដោះស្រាយជម្លោះដោយសន្តិវិធី និងប្រកាន់ខ្ជាប់នូវច្បាប់អន្តរជាតិ ដោយធានាថា ការផ្លាស់ទីលំនៅបន្ថែមទៀតមិនកើតឡើងនៅក្នុងប្រទេសណាមួយឡើយ ហើយជនផ្លាស់ទីលំនៅអាចត្រឡប់ទៅផ្ទះរបស់ពួកគេវិញដោយសុវត្ថិភាព និងចាប់ផ្តើមបន្តជីវិត និងជីវភាពរស់នៅរបស់ពួកគេ។**

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងលោក **វណ្ណ សុផាត** អ្នកសម្របសម្រួលគម្រោង ម.ស.ម.ក តាមរយៈទូរស័ព្ទលេខ (+៨៥៥) ១២ ៩៤១ ២០៦ ឬអ៊ីមែល vann.sophath@cchrcambodia.org។

CC BY NC SA

ខែមីនា ឆ្នាំ២០២៦